# កិច្ចសំភាសន៍បងស្រី រិន មុំ

ក៖ អ្នកដែលសំភាស៏គេ អ៊ុំ ធីដា　　ខ៖ អ្នកដែលអោយគេនិងធ្វើការសំភាស៏រិន មុំ

ក៖ ជាដំបូងសុំជំរាបសួរបង!

ខ៖ ចាស ជំរាបសួរ!

ក៖ ចាស ថ្ងៃនឹងផងដែរខ្ញុំសំណាងល្អដែលបានជួបផ្ទាល់នៅនេះ!

ខ៖ ចាស!

ក៖ ចាសហើយពួកខ្ញុំមកពីសាលា BYU ហើយខ្ញុំស្ម័គ្រនៅខាងសាលានឹងដើម្បីនឹងចុះមកសំភាសន៍បងហើយខ្ញុំនឹងយកសំលេងរបស់បងដាក់នៅក្នុងវេបសាលាដែលនៅខាងសាលាសហរដ្ឋអាមេរិច.....

គ៖ ប្រយ័ត្នមុតណាស់ម៉ាក់វ៉ៃហើយ យកអីមិញ(សំលេងអ្នកនៅក្បែរ)!

ខ៖ យកពងទា!

ក៖ ចាស ហើយគំរោងរបស់សាលានឹងគេចងរក្សាទុកនូវពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាជាពិសេសអ្នកដែលធ្លាប់ឆ្លងកាត់នៅក្នុងសម័យកាលជំនាន់ពលពតហើយសព្វថ្ងៃនេះគាត់មានអាយុ៣៥ឆ្នាំហើយ ចាសថ្ងៃនេះខ្ញុំមានឧកាសបានសំភាសន៍បងផ្ទាល់តើបងស្រីអនុញ្ញាតអោយខ្ញុំបានសំភាសន៍បងដែរឬទេបង?

ខ៖ ចាស អនុញ្ញាត!

ក៖ ចាស អរគុណបងចឹងជាដំបូលបងស្រីមានឈ្មោះអីដែរ? (សំលេងក្មេងស្រែក)!

ខ៖ ខ្ញុំឈ្មោះមុំ!

ក៖ ចាស បងមុំ ឈ្មោះរបស់បងស្រីឈ្មោះពេញឈ្មោះអីដែរបង?

ខ៖ នឹងឈ្មោះបងពេញឈ្មោះនឹងតែគេហៅក្រៅគេចេះតែហៅសុខៗទៅព្រោះបងនឹងឈឺពេក!

កៈ អូ! ចាស!

ខៈ ដល់ឈ្មោះពិតនឹងឈ្មោះមុំនឹង!

កៈ ចាស់ ហើយចុះឈ្មោះពេញនៅក្នុងអត្តសញ្ញាណប័ត្ររបស់បងឈ្មោះអីដែរបង?

ខៈ ឈ្មោះនៅក្នុងអត្តសញ្ញាណប័ត្រដាក់ហាក់ សុខដែនមិនដឹងដាក់សុខមុំនឹងមិនដឹង!

឴ឃៈ ដាក់រិន មុំ!

ខៈ អើ នឹងហើយដាក់ថា រិន មុំ!

កៈ ចាស អឺបង......

ខៈ
ដាក់ឈ្មោះដើមដែរនឹងអត់ដាក់ឈ្មោះក្រៅហៅឈ្មោះនឹងវាចេះតែឈឺពេកនឹងណាក៏ចេះតែហៅៗក្រៅទៅ!

កៈ ចាស បងឈ្មោះក្រុមគ្រួសារបងជាអ្នកដាក់អោយត្រូវទេ?

ខៈ ចាសម៉ែអ្នកដាក់អោយដាក់អោយតាំងតែពីដើមមក!

កៈ អូ! អ្នកម្ដាយបងហ្អែស?

ខៈ ចាស ម៉ែបងដាក់អោយតាំងពីក្មេងមក(សំលេងក្មេងយំ)
តាំងពីកើតមកបានប្រហែលជាមួយខួបចឹងនឹងយើងឈឺពេក
ហើយទៅគ្រូគេថាអោយដូរឈ្មោះអោយហៅសុខ សៅរ៍ចឹងទៅណា
ហើយក៏គេហៅសុខៗចឹងមករហូតមកលែងហៅមុំនឹងទៅតែនៅក្នុងបញ្ជីកំណើតដាក់ឈ្មោះមុំ!

កៈ ចាសបង! ហើយចុះសព្វថ្ងៃនេះបងមានទីលំនៅៗឯណាដែរបង?

ខៈ បងជួលផ្ទះគេនៅ!

កៈ ចាស នៅក្នុងភូមិឃុំអីដែរបង?

ខៈ នៅក្នុងខេត្តព្រៃវែង ស្រុកពាមជរ ខេត្តព្រៃវែង!

កៈ ចាស! នឹងជាទីលំនៅកំណើតត្រូវទេបង?

ខ៖ ចាស ទីលំនៅកំណើត!

ក៖ ហើយចុះទីលំនៅបច្ចុប្បន្នវិញនោះគេហៅភូមិឃុំអីដែរបង?

ខ៖ ខ្ញុំមិនស្គាល់ទេនៅកន្លែងនេះ គេហៅភូមិឃុំអីគេបង?

ឃ៖ ភូមិអីគេ?

ខ៖ ផ្ទះជួលយើងរាល់ថ្ងៃនេះគេហៅភូមិអី?

ឃ៖ បឹងស្រឡាង!

ខ៖ នៅបឹងស្រឡាងអូន!

ក៖ ចាស ហើយឥលូវនឹងបងបានរៀបអាពាពិពាហ៍ហើយត្រូវហ្អែស?

ខ៖ ចាស!

ក៖ ចាស ហើយសព្វថ្ងៃបងមានមុខរបរជាអីដែរបង?

ខ៖ រត់កង់បី អឺប្តីរបស់បងគាត់រត់កង់បី!

ក៖ អូចាស! ស្វាមីរបស់បងរត់កង់បី ហើយចំណែកបងសព្វថ្ងៃ......

ខ៖ មើលកូន!

ក៖ មើលកូន ចាសបងមានកូនប៉ុន្មាននាក់ហើយ?

ខ៖ បីនាក់អូន!

ក៖ បីអ្នកហើយ!

ខ៖ ចាស ស្រីពីរប្រុសមួយ!

ក៖ ចាស ពួកគាត់ទាំងអស់គ្នាអាយុប៉ុន្មានខ្លះបង?

ខ៖ ១១ឆ្នាំមួយ ៦ឆ្នាំមួយ ៧ខែមួយ!

ក៖ ចាស ចឹងកូនរបស់បងបានចូលសាលារៀនខ្លះហើយ?

ខ៖ ចាស ចូលសាលារៀន!

ក៖ ចាស នៅឯណាដែរបង?

ខ៖ នៅស្រុក!

ក៖ អូ ពួកគាត់អត់បាននៅភ្នំពេញទេតែគាត់នៅស្រុកវិញហ៎បង?

ខ៖ ចាស នៅស្រុកនៅរៀនជាមួយយាយ!

ក៖ ចាស ហើយស្រុករបស់នៅខាងព្រៃវែង?

ខ៖ ចាស នៅខេត្តព្រៃវែង!

ក៖ ចាស ហើយចឹងបងនឹកកូនហើយកូននៅណោះបងនៅនេះ(សើច)!

ខ៖ ចាសនឹក(សើច) តេម្សិលមិញថាម៉ោថ្ងៃនឹងតែមិនទាន់ឃើញមកដល់!

ក៖អូ! ចឹងជាធម្មតាគាត់មកលេងបងរយះពេលប៉ុន្មានដែរបង?

ខ៖ ហើយជាប់រៀនចឹងមិនងាយទេ ទាល់តែវ៉ាកងៗធំអីចឹងទៅបានមក នេះឈប់ពីរបីថ្ងៃនឹងបានមកលេងនឹងមកលេងដេកបានតែពីរយប់នឹងទៅវិញបាត់ហើយ ព្រោះជាប់រៀនចឹងបងក៏មិនហ៊ានឃាត់អោយកូននឹងនៅយូរដែរខ្លាចវារៀនមិនទាន់គេអូន ទាល់តែមានបុណ្យទានម្តងៗចឹងទៅបានអោយកូនមកលេងហើយបើមិនចឹងបងទៅលេងកូនវិញទៅតែបើបងទៅវាខាតការងារចឹងហើយមានតែពេលឈប់ល្មមនឹងៗអោយកូនមកលេងទៅ!

ក៖ ចាស! ចុះគាត់រៀននៅស្រុកនឹងថ្នាក់ទីប៉ុន្មានហើយបង?

ខ៖ ថ្នាក់ទៅ៥!

ក៖ ថ្នាក់ទីប្រាំហើយសព្វថ្ងៃបងមានទីលំនៅៗនេះហើយពេលដែលបងរៀបអាពាពិពាហ៍ហើយបងអត់ធ្វើការអីដែរគឺបងនៅមើលថែកូន!

ខ៖ ចាស នៅមើលថែកូនៗ!

ក៖ចាស ហើយចុះស្វាមីរបស់បងមានឈ្មោះអីដែរ?

ខ៖ គាត់ឈ្មោះម៉ាន់!

ក៖ គាត់ឈ្មោះលោកពូម៉ាន់?

ខ៖ ចាស!

ក៖ ចាស ហើយគាត់មានស្រុកកំណើតនៅឯណាដែរបង?

ខ៖ គាត់នៅនឹងភ្នំពេញនឹងគីឡូលេច៦នឹង!

ក៖ ចាស
ចុះកាលដែរបងរៀបការជាមួយលោកពូកាលនឹងបងស្រលាញ់គ្នាឬមួយក៏ឪពុកម្ដាយទុកដាក់អោយ?

ខ៖ ស្រលាញ់គ្នា!

ក៖ ស្រលាញ់គ្នាបងហ៎?

ខ៖ ចាស! (សើច)!

ក៖ (សើច) ចាសបង
ហើយបន្ទាប់មកពេលដែលបងផ្លាស់មកទីក្រុងភ្នំពេញនឹងដោយសារតែបងជាមួយលោកពូឬមួយក៏បងមកសំរាប់ធ្វើការងា?

ខ៖ មកនៅជាមួយប្ដីរកស៊ីហើយក៏ធ្វើការនៅនឹង!

ក៖ រយះពេលប៉ុន្មានឆ្នាំងយើងបង?

ខ៖ យូរដែរហើយបីឆ្នាំហើយ!

ក៖ ប្រហែលជាបីឆ្នាំហើយន៏បងស្រី?

ខ៖ ចាស តាំងពីកូនមួយឥលូវកូនពីរហើយ!

ក៖ ចាស!

ខ៖ ថាទៅបីឆ្នាំហើយបងមកនៅនឹងបីឆ្នាំហើយ ជិតបីឆ្នាំហើយថាបីឆ្នាំចុះ!

ក៖ កំណើតកូនទីប៉ុន្មានដែរបងៗបងមកនៅទីនេះ?

ខ៖ កំណើតកាលនឹងកូនបងមីបង
អឺមអត់ហ្អេកំណើតមីកណ្ដាលនៅតូចដែរតែដេកលក់បាត់ហើយ!

កៈ ចាស ហើយកូនរបស់បងម្នាក់ៗនឹងពួកគាត់ឈ្មោះអីខ្លះទៅបង?

ខៈ ឈ្មោះឆី ឆីង ហើយនឹងឌិន!

កៈ អូ ឈ្មោះពិរោះៗមែនទែនឈ្មោះដូចចិន (សើច)!

ខៈ (សើច) អឹមជីតាគេនិងពូគេនឹងឃើញឈ្មោះពិរោះៗចឹងក៏យកមកដាក់អោយក្មួយទៅស្រលាញ់ចៅស្រលាញ់ក្មួយណាស់!

កៈ យកហ៊ុងស៊ុយដឹងបង?

ខៈ ចាស យកហ៊ុងស៊ុយ (សើច)!

កៈ (សើច) !

ខៈ ឆី ឆីង ឌិនឈ!

កៈចាស ឈ្មោះកូនបងទាំងបីនឹងបងជាអ្នកដាក់អោយឬក៏ខាងណាជាអ្នកដាក់អោយដែរបង?

ខៈ អឹម មួយនោះជីតាគេដាក់គេ
ហើយពីរទៀតនោះពូគេស្រលាញ់ឈ្មោះនឹងក៏ចេះតែដាក់អោយទៅ!

កៈ អូ ចាស(សើច) គាត់ស្រលាញ់!

ខៈ ចាស ពូរបស់គេអ្នកដាក់អោយ(សើច)! ឈ្មោះឆីងនឹងពូគេអ្នកដាក់អោយ
យើងឈ្មោះឆីនឹងតាគេអ្នកដាក់អោយ(សើច)
អោយតែទៅលេងស្រុកម្តងៗនឹងនិយាយពីថាម្នាក់ស្រលាញ់ណាស់យកទៅដើរលេងចឹងទៅមិនសូវជាបាននៅជាមួយបងទេពេលទៅផ្ទះនឹងពីផ្ទះទៅផ្ទះមួយនឹងទាល់តែបានមករកបង!

កៈ ហើយអឹចឹងពេលនេះដែរបងបានរៀបការជាមួយនឹងបងប្រុសរួចហើយក៏បង្កើតបានជាគ្រួសារមួយមានកូនបីនាក់ទៀត តែកាលពីមុនដែលបងរស់នៅក្នុងខេត្តព្រៃវែងនឹងបងមានមុខរបរជាអីដែរ?

ខៈ បងធ្វើចំការអូន
បងនៅធ្វើស្រែធ្វើចំការជាមួយម៉ែឪរបស់បងជួយគាត់ទៅណាស់ដូចថាកាលនោះយើងក៏មិនដឹងថាទៅរកអីដែរមានតែជួយពួកគាត់ធ្វើស្រែធ្វើចំការនឹងទៅណាមួយយើងធ្វើចឹងទៅវាមុខរបររបស់យើងហើយមានអីក្រៅពីនឹងធ្វើការអោយតែខ្លួន

ឯងនឹងមិនទៅធ្វើការអ្នកណាយើងចង់ឈប់ក៏ឈប់ទៅចង់ទៅធ្វើក៏ទៅធ្វើទៅស្រេចតែចិត្តយើងទេ!

ក៖ ដាំអីដែរបង?

ខ៖ ដាំឪឡឹក សណ្តែក ពោត ដល់ខែដាំសណ្តែកដាំសណ្តែក ខែកាច់ពោតនឹងកាច់ពោតហើយដាំសណ្តែកទៀតទៅនិយាយដល់អីដាំនឹង ដូរដំណាំរហូតនឹងដូចថាយើងផ្លាស់ប្តូរទៅតាមរដូវចឹងណាស់!

ក៖ ដូរប្រភេទដំណាំរហូតចឹងទៅ?

ខ៖ ចាស ដូរប្រភេទដំណាំដូចពីមួយរដូវទៅមួយរដូវគមានប្រភេទដែលគេត្រូវដាំចឹងណាស់អូន ហើយបើយើងដាំវាខុសរដូវធ្វើអោយយើងប្រមូលផលមកមិនបានច្រើនទេហើយជួនកាលនឹង នឹងដូចយើងយកលុយទៅចោលចឹងណា!

ក៖ គេមានរដូការដាំនឹងទៅតាមរដូវហ្អេសបង?

ខ៖ នឹងហើយគេមិនមែនចេះតែដាំទេគេមានទៅតាមរដូវរបស់គេ ដល់ខែសណ្តែកយើងដាំសណ្តែកយើងដាំសណ្តែកទៅ ដល់ខែពោតយើងដាំពោតទៅ ហើយគេមើលទៅតាមប្រភេទដីនឹងទៅបើដីណាអាចដាំពោតបានគេដាក់ពោតទៅ ហើយដីណាដាំសណ្តែកបានគេដាក់សណ្តែកនឹងទៅ ដីណាដែលធ្វើមិនបាននោះគេទុកវាធ្វើអីផ្សេងទៅដាក់ពោត ដាក់ស្រូវអីចឹងទៅ អ្នកចំការគេដឹងថាដាក់អីបានផលច្រើនចឹងណាស ហើយគេដាក់ដាំអីមួយនឹងត្រូវមើលលើដីដែលមិនចេះតែដាំៗទៅទេ បើមិនចឹងដាំទៅយើងមិនទទួលបានផងទេ ដាំទៅដូចយកទៅបោះចោលចឹងណាស ពេលដាំក៏គេត្រូវមើលលើទៅផ្សារដែរថាពេលដាំនឹងពេលប្រមូលផងនឹងយើងអាចលក់វិញបានប៉ុន្មានដែរ បើមិនចឹងទេអត់រួចខ្លួនទេអូន ធ្វើចំការមិនចេះតែធ្វើៗទៅទេត្រូវគិតច្រើនតិចបើមិនចឹងយើងព្រោះពេលខ្លះយើងយកលុយគេមកធ្វើចំការចឹងបើពេលេលប្រមូលផងលក់ទៅមិនរួចខ្លួនធ្វើម៉េចនឹងបានលុយសងទៅគេវិញវាចឹងណាសអូន មិនមែនចង់ដាំស្តែៗឃើញគេដាំឪឡឹកដាំឪឡឹកតាមគេចឹងទេ បើយើងដាក់ខុសយើងច្បាស់ណាសត្រូវជំពាក់គេហើយ!

កៈចាស ចឹងកាលពីបងនៅឯណោះនៅជាមួយឪពុកម្តាយរបស់បងហ៎?

ខៈ ចាសនឹងហើយនៅជាមួយម៉ែឪនឹង!

កៈចាសហើយចុះឪពុកម្តាយរបស់បងឈ្មោះអីដែរបង?

ខៈ គាត់ឈ្មោះស្រិន ស្រៀន!

កៈ អឺ........

ខៈ ម៉ែបងឈ្មោះស្រិន ស្រៀន ឪពុកបងឈ្មោះរីម!

កៈ ឈ្មោះពេញរបស់គាត់ឈ្មោះអីដែរបង?

ខៈ បងអត់ចាំ ព្រោះឈ្មោះគាត់តាមចាស់បុរាណមកនោះ!

កៈ ចាសបង!
ចឹងគាត់មានស្រុកកំណើតនៅស្រុកព្រៃវែងនឹងឬក៏គាត់ផ្លាស់ពីណាពីណីមកដែរ?

ខៈ គាត់ថានៅសម័យណាមិនដឹងទេ ហើយគាត់ថាគាត់ធ្លាប់ទៅរស់នៅយ៉ូត
តែមិនដឹងថាយ៉ូតនឹងនៅឯណាផងនឹង
យើងលឺតែគាត់និយាយតាំងពីយើងនៅតូចៗមកម្លេះតែយើងក៏មិនដឹងថាយ៉ូតនឹងនៅឯណាទេ
ម៉ែគាត់ធ្លាប់ប្រាប់ដែរថាកាលពីបងនៅតូចៗនឹងធ្លាប់ទៅលេងនៅស្រុកយ៉ូតនឹងដែរតែដូចថា
យើងនៅតូចពេកមិនដឹងមិនចាំអីណាសកាលណោះនៅក្មេងពេកយើងមិនចាំណាសអូន!

កៈ នៅស្រុកយ៉ូតហ៎បង?

ខៈ ចាស លឺតែគាត់និយាយចឹងយើងមិនស្គាល់ដែរ
គាត់ថាគាត់រស់នៅនឹងរហូតដល់មានកូនពីរបានបែកមករស់នៅទីនេះនៅព្រៃវែកនឹង!

កៈ ចាស ហើយសព្វថ្ងៃបងចេះប៉ុន្មានភាសាដែរបង?

ខៈ ហ៊ើយបងមិនចេះអីផង!

កៈ អត់ចេះ?

ខៈ តែអក្សរនឹងក៏បងមិនចេះផង
បងឈប់រៀនយូរដែរហើយតាំងពីនៅក្មេងៗណោះមិនបានរៀនច្រើនដូចគេអី

បើបងរស់តែនឹងខ្មាសគេនឹងហើយណាមួយយើងរៀនមិនចូលផងខួរក្បាលយើងបាប់វាមិនស្វជាបានដូចគ្នាណាសអូន!

ក៖ ម៉េចចឹងបង?(សើច)

ខ៖ (សើច) មិនមែនទេរៀនតែនៅតូចៗខូចខ្ជិលរៀន ហើយខាតរៀនយូរហើយយើងមិនចេះណាមួយខួរក្បាលយើងមិនស្វល្អផងល្មមៗនឹងមិនចាំទេ និយាយទៅកាលនឹងយើងដូចថានៅក្មេងផងមិនដឹងថាចង់ចេះដឹងអីគេណា មិនដូចឥលូវឃើញគេចេះដឹងមានការងារល្អធ្វើចឹងបានដឹងថាស្តាយក្រោយចង់ទៅរៀនវិញក៏ហួសពេលអស់ហើយ បើបងចំណាស់នេះទៅហើយនឹងមិនមានពេលឯណានឹងទៅរៀនទៀត បើពីកាលដែរនៅក្មេងៗនឹងយើងមិនព្រមខំរៀននឹងគេគិតតែពេញរូបពេញរាងខ្មាសគេមិនទៅរៀន!

ក៖ បងរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ហឹម បងរៀនបានត្រឹមថ្នាក់ទីរពីរទីរបីអីនឹង ថ្នាក់ទីពីរទីរបីនៅជំនាន់១៩៧៩មកដល់យើងឥលូវនឹងវារង្វេងវង្វាន់អស់ហើយមិនដឹងស្អីជាស្អីទេអូនសួរអីក៏មិនចាំដែរ តែអានអក្សរក៏ភ្លេចអស់ទៅហើយអូនអានក៏មិនដាច់ដែរដូចថាយើងវាខានរៀនយូរហើយ!

ក៖ ចាស ចុះកាលនឹងបងរៀនសាលាណាដែរ?

ខ៖ សាលាខ្មែរយើងធម្មតានឹង សាលារដ្ឋយើងនឹងអូន!

ក៖ ចាស ចុះបងមានចាំឈ្មោះសាលាបងធ្លាប់រៀននឹងទេ? សាលារៀននឹងឈ្មោះអី?

ខ៖ អឹម! អត់ដាក់ឈ្មោះសាលាបឋមដូចសម័យនេះទេ គ្មានឃើញដាក់ឈ្មោះអីផងមានតែជុំគ្នាហើយរៀនម៉ងទៅគ្មានទៅមានសាលាត្រឹមត្រូវណាទេ ទាំងគ្រូទាំងសិស្សនឹងចាំមើលតែជុំគ្នាទៅនាំគ្នារៀនទៅមិនដូចឥលូវមានសាលាត្រឹមត្រូវចឹងអី សម័យនោះមានតែតុអង្គុយរៀនអោយស្រួលទៅអរណាស់ទៅហើយ កាលណោះសាលាខ្វះសំភារះច្រើនមិនមែនតែសំភារះទេតែសាលានឹងក៏គ្មានដែរទៅរៀនម្តងៗនឹងរៀននៅក្នុងវត្តនឹងមានសាលាឯណានឹងរៀននឹងគេដូចក្មេងឥលូវកាលណោះហ៎!

ក៖ ពេលជុំគ្នាហើយក៏រៀនទៅ?

ខ៖ នឹងហើយពេលមកជុំគ្នានាំគ្នារៀន តែសាលារៀននៅក្នុងវត្ត
ហើយយើងទៅរៀននៅក្នុងសាលាលោកនឹងទៅ!

គ៖ សាលាកាលនឹងមានតែក្តារៀនមួយនឹងគ្មានឈ្មោះគ្មានអីទេ!

ក៖ ហើយចុះវត្តនឹងគេហៅវត្តអីដែរបង?

ខ៖ គេហៅវត្តនឹងវត្តយើងស្វាយក្រៀលនឹង!

ក៖ អូ! ចាស ហើយបងកាលនឹងហើយឈប់រៀនដោយខ្លួនឯងទេន៍?មិនមែនមានអ្នកបង្ខំទេ?

ខ៖ ឈប់ខ្លួនឯងគ្មានអ្នកណាបង្ខំ(សើច)!

ក៖ (សើច) ឈប់ហើយធ្វើការម៉ាក់ម៉ងទៅ?

ខ៖ មិនមែនទេអញ្ចេះ!! យើងរៀនៗថ្នាកទី១១ ទី១២ នឹង ហើយកាលយើងវាអាយុប្រហែល១២ ១៣
អីហ្នឹងវាពេញរូបពេញរាងហើយរាងកាយយើងចេះតែវិត្តន៍ទៅពេលពាក់អាវទៅវាចេញរូបរាងដាក់គេហើយចេះតែខ្មាស់គេអីចឹងហើយខ្ជិលទៅរៀនម៉ងទៅហើយក៏ឈប់រៀន(សើច)យើងវាឆាប់ពេញវ័យណាស់ហើយកាលសម័យនោះមិនសូវជាសំបូរខោអាវដូចយើងសព្វថ្ងៃនេះអីចឹងហើយវាពិបាកពេលដែលទៅសាលាម្តងៗនឹងព្រោះយើងជាមនុស្សស្រីវាមិនគេមនុស្សប្រុសឯណាគេខោអាវហើយៗ
ឯងនៅមានអាវក្នុងអាវក្រៅរញ៉េរញ៉ៃធុញណាស់ពាក់ម្តងៗតែមិនពាក់ក៏មិនកើត
ណ្ហើយចេះតែទ្រាំពាក់ទៅ ហើយក៏ឈប់រៀនទៅណាមួយយើងវាខ្វះខាតផង!

ក៖ ចាស ហើយចឹងបងក៏ឈប់រៀនទៅ? ហើយក៏ជួយការងាផ្ទះឪពុកកម្តាយចឹងទៅ?

ខ៖ រៀននឹងចេះតែនៅរៀនគេមិនទាន់ឈប់ទេកាលនឹង
ហើយរហូតដល់ពេលបងដល់វ័យគ្រប់ការទៅ(សើច)
ក៏បងខ្មាស់គេក៏ឈប់ទៅដូចថាយើងពេញក្រមុំទៅខ្មាស់គេបងអៀនច្រើនណាសហើយចឹងក៏ឈប់ទៅរៀនទៅម៉ែឪគាត់ជំរុញអោយទៅដែរតែគ្រាន់តែថាយើងខ្លួនឯងនឹងខ្ជិលរៀនខ្លួនឯងរៀនមិនចូលនឹងណាស់!

ក៖ (សើច) ចាស! ហើយចឹង អឺ ចឹងបងស្រីសព្វថ្ងៃមានបងប្អូនដែលគាត់.......

ខ៖ ទើបផឹកគោជល់មិញ ឥលូវទារយកមួយកំប៉ុងទៀតហើយនៅមួយកំប៉ុងនឹង (សំលេងក្មេងយំ) អូយៗ ហៀរមែន មានប្រលាក់អត់នឹង?

ក៖ ចាស ហើយពេលដែលបងបានឈប់ពីការរៀនសូត្រហើយជួយធ្វើការឪពុកម្តាយនឹងកាលនឹងមានចាំថាបងមានអាយុប៉ុន្មានដែរ?

ខ៖ នឹងអាយុប្រហែល១៤, ១៥ នឹង ធ្វើការៗបងក៏ឈឺហើយក៏នៅជាមួយម៉ែឪរហូតដល់សព្វថ្ងៃនឹងទៅ!

ក៖ ចាស!.......

ខ៖ យើងឈឺមិនឈប់!

ក៖ ហើយបងកាលនឹងពេលដែលធ្វើការងារ ហើយក្រោមកក៏ទៅរស់នៅជាមួយឪពុកម្តាយរបស់វិញ ហើយបងស្រីអាយុប៉ុន្មានដែរដែលបងសំរេចចិត្តរៀបអាពិពាហ៏?

ខ៖ បងអាយុប៉ុន្មានទេ ប្រហែលជាខ្ទង់២០ ឆ្នាំអីនឹងហើយតាមមើលព្រោះកាលនឹងបងនៅរៀងក្មេងដែរណាសអូនពេលដែរបងរៀបការនឹងនៅរៀងក្មេងមិនសូវជាដឹងអីដែរនឹង!

ក៖ ប្រហែលជាអាយុ១០ឆ្នាំជាងជិត២០អីហ្អែសបង?

ខ៖ អត់ទេបងរៀបការនៅអាយុ២០ ឆ្នាំ (សំលេងក្មេងយំ) នឹង២០ឆ្នាំនឹងហើយត្រូវហើយ២០ឆ្នាំបានបងរៀបការមានគ្រួសារនឹង!

឴ឃ៖ ហ៎ ដំលូងឆឹងចេកឆឹងក្តៅហ្អា!

ក៖ ចាស ហើយពេលដែលបងសំរេចចិត្តថាមានរៀបការមានគ្រួសារក្រោយមកបងមានដែលមានអារម្មណ៏ថាចង់ទៅរៀនវិញដែរឬអត់ទេ?

ខ៖ អត់ទេ!

ក៖ អត់ទេហ៎បង! ដាចើម៉ងហ្អែស? (សើច)!

ខ៖ ដាច់ម៉ង! (សើច) មានប្តីមាកូនហើយកាន់តែខ្ជិលថែមទៀតហើយ
រៀនទៅក៏រៀនមិនចូលដែរបើកូនពីមុខពីក្រោយចឹងនុះ
ហើយណាមួយយើងគ្មានពេលនឹងទៅរៀនអីទៀតទេអូនពេលមានគ្រួសារវាមិនស្រួលដូចជា
យើងនៅលីវទេ ទៅណាមួយចំហ៊ានត្រូវគិតដល់កូនគិតដល់ប្តីបាយទឹកកូន
ហើយគិតសព្វគិតគ្រប់នឹងបានអីនឹងរៀនចូលទៅអូន!

ក៖ (សើច) ចាស!

ខ៖ គ្មានទៅចេះអក្សរមួយទេបងនោះ!

ក៖ ចាស ហើយចុះបងមានបងប្អូនប៉ុន្មាននាក់បង?

ខ៖ បងមានបងប្អូនទាំងអស់នឹង៧ នាក់!

ក៖ ចាស ហើយពួកគាត់មានឈ្មោះអីខ្លះដែរបង?

ខ៖ កូនបងគេត្រូវជាបងរបស់បងនឹងឈ្មោះ ឈាន់ ស្រ៊ាន់  បន្ទាប់មក ហៀង នុល តុក សារឿន
អាចង តែប៉ុន្នឹងអស់ហើយ!

ក៖ ចាសបងស្រី បងមានបងប្អូនទាំងអស់៧នាក់
ហើយចុះបងមានចាំឈ្មោះពេញរបស់ពួកគាត់ទេបង?

ខ៖ អឺម បងមិនចាំទេ ដឹងតែឈ្មោះចឹងៗម៉ងអោយចាំណាទៀតអត់ចាំទេ!

ក៖ឈ្មោះទាំងត្រកូលនឹងបងអត់ចាំទេ?

ខ៖ អត់ចាំផងអូន!

ក៖ ចាសបង ហើយអឺ!! ចឹងបងនឹងបងប្អូនរបស់នឹងរស់នៅបែកគ្នាហ៍បង?

ខ៖ ចាស រស់នៅបែកគ្នាអូន!

ក៖ ចាស ចុះពួកគាត់រៀបអាពិពាហ៍ប៉ុន្មានគ្រួសារហើយបង?

ខ៖ រៀបការមានគ្រួសារអស់ហើយអូន (សំលេងក្មេងយំ)!

ក៖ អូ!! ចាសពួកគាត់មានគ្រួសារអស់ហើយន៏បង?

ខ៖ ចាស នៅមួយដែរតែវាខូចជើង!

កៈ ចាស ហើយអឺ!! អឺ គាត់នៅណាដែររាល់ថ្ងៃ? បងៗនិងប្អូនរបស់បងស្រីពួកគាត់រស់នៅឯណាដែររាល់ថ្ងៃនឹង?

ខៈ នៅធ្វើការនៅបែកចាន២អ្នក ហើយនៅពោធិ៍ចិនតុង២អ្នក ហើយនៅស្រុកស្រែម្នាក់ ហើយនៅច្បារអំពៅយើងនឹងមួយ ហើយនៅឯស្រុកតែមួយទេ ក្រៅពីនឹងមកធ្វើការនៅភ្នំពេញទាំងអស់នឹង អូ នៅឯស្រុកនឹងពីរអ្នកនៅអាមួយពិការជើងមួយទៀត ធ្វើការប៉ះម៉ូតូកង់អីនឹង!

កៈ ហើយចុះបងស្រីធ្លាប់ទៅលេងស្រុកដែរទេ?

ខៈ ទៅតើ!

កៈ មួយឆ្នាំបងទៅលេងស្រុកប៉ុន្មានដងដែរបង?

ខៈ អឹម! មិនទៀងដែរ មិនសូវជាទៅដែរ បី បួនខែ អីទៅលេងស្រុកម្តងចឹងទៅ ពេលខែបុណ្យទានទៅក៏នាំគ្នាទៅលេងស្រុកចឹងទៅជុំគ្នីគ្នាចឹងទៅណាព្រោះបើយើងទៅខុសខែបុណ្យក៏មិនសូវជាបានជុំគ្នាដែរបើម្នាក់ៗនៅធ្វើការរៀងខ្លួននឹងទាល់តែមានបុណ្យទានចំថ្ងៃគេឈប់អីទៅបានយើងទៅលេងស្រុកបានជុំគ្នាច្រើនសប្បាយណាអូន!

កៈ ចាសបង! ចឹងយូរៗបងទៅលេងផ្ទះម្តងចឹងនឹកផ្ទះខ្លាំងហើយមែនទេបង?

ខៈ ពេលណានឹកផ្ទះខ្លាំងទៅនៃគ្នាទៅលេងផ្ទះទៅបើមិននឹកទេទាល់តែខែចូលឆ្នាំថ្មី ខែភ្ជុំបិណ្ឌបានទៅលេងផ្ទះ បើអត់នឹកអត់ទៅលេងផ្ទះដែរនឹង!

កៈ ចាស សព្វថ្ងៃឪពុកម្តាយរបស់បងស្រីគាត់អាយុប៉ុន្មានហើយ?

ខៈ ពួកគាត់៦០ឆ្នាំជាងហើយ ចាស់ៗអស់ហើយអូន!

កៈ ទាំងឪពុកទាំងម្តាយហ្អែសបង?

ខៈ ចាស នឹងហើយអូន សុទ្ធតែ៦០ជាងអស់ហើយ!

កៈ ចាស ចឹងពួកគាត់មានអាយុប្រហាក់ប្រហែលគ្នាបង?

ខៈ ចាស គាត់មិនមែនអាយុដំណាលគ្នាទេអាយុលើសគ្នា៣ ទៅ៤ ឆ្នាំដែរ!

កៈ អូ! ចឹងម្តាយបង..........

ខ៖ គាត់អាយុលើសគ្នាដូច ៦៥,៦៦,៦៧ អីចឹងទៅណា!

ក៖ ចាសៗ បង.......

ខ៖ ម៉ែបងអាយុ៦៥ ឆ្នាំអីនឹង បងគ្នាតិចតួចនឹងណាស់!

ក៖ ចាសបង!
ហើយចុះបងប្អូនរបស់បងស្រីពួកគាត់មានអ្នកណាដែលបានស្លាប់នៅក្នុងសម័យពលពតដែរទេបង?

ខ៖ (សំលេងក្មេងយំ) ឈប់សិនអូន (សំលេងនៅឆ្ងាយ) សុំសួរម្តងទៀតមកអូនមិញអាឡើយតែជាប់រវល់នឹងកូន
ចឹងណាអូនបានថាទៅណានឹងគេកើតអូនឯងឃើញស្រាប់ហើយយើងមានកូនតូចវាមិនស្រួលទេ ងាយកូននឹងវាអញ្ចេះទៅងាកទៅវាអញ្ចុះទៅពិបាកណាស់អូននៅបំរើតែកូនឯងគ្មានបានទៅណាស្រួលដូចគេ!

ក៖ ចាសបងស្រីមានបងប្អូន៧ នាក់
ហើយចុះបងប្អូនរបស់បងពួកគាត់មានអ្នកណាស្លាប់នៅក្នុងសម័យពលពតដែរទេ?

ខ៖ អត់មានទេអូន អត់មានហេ! ( សំលេងក្មេង)

ក៖ ចាស! ចឹងពួកគាត់សុទ្ធតែរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះ!
ហើយចុះបងស្រីបានធ្លាប់បានឆ្លងកាត់នៅក្នុងជំនាន់ពលពតដែរឬទេ?

ខ៖ ចាស សុំម្តងទៀត?

ក៖ បងស្រីមានដែលធ្លាប់ឆ្លងកាត់ជំនាន់ពលពតដែរឬទេ?

ខ៖ អូ!! អត់ទេអូន បងទាន់នឹងបែកពី ១៩៧៩ ហើយ!

ក៖ ចាស ហើយចុះសព្វថ្ងៃបងអាយុប៉ុន្មានហើយបង?

ខ៖ បងហ្អែស?

ក៖ ចាសបង!

ខ៖ បងអាយុ ៤០ឆ្នាំហើយ!

កៈ ៤០ ឆ្នាំហ៎បង?

ខៈ ចាស!

កៈ ចាស ចឹងបងស្រីកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរបងមាននៅចាំដែរទេ?

ខៈ បងមិនចាំទេ តែដឹងតែថានៅក្នុងឆ្នាំ ១៩៧៩ (សំលេងកូនក្មេង)!

កៈ ចាស ហើយចុះអត្តសញ្ញាណប័ត្របងវិញ?

ខៈ អត្តសញ្ញាណប័ត្រងបងនឹងមាននៅក្នុងឆ្នាំ ១៩៧៩ ក៏ ១៩៨២ ទេនេះ!

កៈ ចាស ហើយបងមាននៅចាំថ្ងៃខួបកំណើតរបស់បងដែរទេ?

ខៈ និយាយទៅបងមិនចាំទេ ទាល់តែមើលនៅក្នុងអត្តសញ្ញាណប័ណ្ណអីណ៎បានចាំកាលនឹងបងធ្វើនៅក្នុងបញ្ជីជាតិហើយកាលនឹងយើងធ្វើយូរហើយបងភ្លេចបាត់អស់ទាល់តែសួរម៉ែបានគាត់ចាំបើបងមិនចាំទេ។

កៈ ចាស ប៉ុន្តែដឹងតែថាបងកើតនៅឆ្នាំ១៨៧៩ នៅពេលដែលបែកពីពលពតនឹងន៎បង?

ខៈ ចាសអូន!

កៈ ចាស បងសំណាងមែនទែនដែលមិនកើតមកចំជំនាន់នឹងណា ព្រោះនៅជំនាន់នឹងយើងពិបាក(សើច)!

ខៈ (សើច) ជំនាន់ពលពតទាល់តែបងខ្ញុំបានទាន់បើបងអត់ទាន់ទេ!

កៈ ហើយបងចុះចំណែកបងប្អូនរបស់បងសព្វថ្ងៃនេះពួកគាត់ទាំងអស់គ្នាប្របកបរបរអីដែរ?

ខៈ អឺម មួយធ្វើនៅក្នុងហាងលាងចានអោយគេ ហើយពីរទៀតធ្វើការរោងចក្រ!

កៈ អូ! ចាសបង គាត់ធ្វើការរោងចក្រណាដែរបង?

ខៈ ន៎!!! ធ្វើនៅជំពូវន្តមម្នាក់នៅលូ៥ មួយនឹងជំពូវន្ត!

កៈ ចាស ពួកគាត់ធ្វើការនៅភ្នំពេញ!

ខៈ ចាស អូន!

កៈ ហើយបងប្អូនរបស់បងគាត់ធ្វើការនៅភ្នំពេញទាំងអស់គ្នាហ្អែសបង?

ខ៖
អត់ទេអូននៅតែអ្នកដែលមានគ្រួសារហើយក៏បែកមករស់នៅភ្នំខ្លះទៅហើយខ្លះទៀតក៏នៅស្រុកទៅបើបងរបស់បងគាត់នៅស្រុកធ្វើស្រែចំការនឹងធ្វើការតិចតួចនៅនឹងស្រុកនឹងទៅមានតែពីរនាក់ទេនៅស្រុកនឹងនៅសល់ប៉ុន្មានមកធ្វើការនៅភ្នំពេញអស់ហើយ
នៅលីវមួយដែរតែវានៅឯស្រុកហើណាមួយគ្នាពិកាណាអូន មានអ្នកណាគេយកយើងទេ!

ក៖ ចាស
ហើយបងពេលដែលរៀបអាពាពិពាហ៍ហើយចឹងបងគិតថាជីវិតរបស់បងមុនពេលរៀមអាពាពិពាហ៍និងក្រោយពេលរៀបអាពាពិពាហ៍ហើយខុសគ្នាម៉េចដែរបង?

ខ៖ ខុសគ្នានោះគឺប្រាកដជាខុសហើយអូន
ពេលដែលយើងមានប្តីយើងត្រូវមានទំនួលខុសត្រូវច្រើនមានកិច្ចការច្រើនត្រូវធ្វើ
ហើយក៏កើតទុក្ខច្រើនណាសដែរ
នៅផ្ទះត្រូវមើលថែកូនមើលថែប្តីតិចទៅកូនឈឺត្រូវនាំកូនទៅពេទ្យ
ត្រូវគិតពីការងាររកស៊ីរាល់ថ្ងៃ
ពេលខ្លះទៅធ្វើបាបមិនយល់ចិត្តគ្នាពេលណាគេផឹកស្រវឹងទៅវ៉ៃម៉ូតូវ៉ៃអីសព្វបែបយ៉ាងទៅណា
មិនដូចជាជីវិតនៅលីវទេនៅលីវយើងមិនដែលទៅកើតទុក្ខអី
គ្មានទៅខ្វល់ឈឺក្បាលបាលថ្ងៃជាមួយអ្នកណា
យើងនៅលីវផ្សេងយើងនៅលីវមានទៅពិបាកចិត្តអី?
ដឹងតែទារលុយពីរម៉ែពីឪទៅជូនណាទៅយើងមានការធ្វើខ្លួនឯងចឹងទៅរកលុយបានអោយម៉ែទុកដាក់ចឹងទៅ ដល់ពេលដែលយើងមានប្តីគឺខុសប្លែកពីគ្នារកលុយបានយើងទុកខ្លួនឯងទុកមើលកូនឈឺទុកទិញម្ហូបខោអាវកូន
ណាលុយកូនរៀនហើយជូនណាទៅយើងនឹងឈឺទខ្លួនឯង
ជីវិតពេលដែលនៅលីវយើងមានសេរីភាពចង់ដើរហើយទៅណាក៏បាន
មិនដូចយើងមានប្តីពេលដែលមានគ្រួសារជីវិតចាប់មានបន្ទុកច្រើនឡើងចង់ដើរហើរទៅណាក៏មិនបាន ចង់ដើរទៅណាទាល់តែនាំកូននាំប្តីទៅហើយយើមានកូនតូចឹងវាមិនស្រួលទេ!

ក៖ ចាស
ហើយមុនពេលដែលរៀបអាពាពិពាហ៍នឹងបងរស់នៅជាមួយនឹងឪពុកម្តាយរបស់បង?

ខ៖ នឹងហើយអូនបងនៅជាមួយម៉ែឪបង ហើយបងក៏មកធ្វើការទៅ!

ក៖ បងធ្វើការអីដែរបង?

ខ៖ ធ្វើការនឹង!
អឹម.....ពីដំបូងនឹងបងធ្វើស្រែចំការជាមួយឪពុកម្ដាយនៅស្រុកនឹងតែក្រោយមកបងខ្ជិលធ្វើស្រែចំការក៏មកធ្វើការអោយគេនៅក្នុងហាង បោសជូតហាងអោយគេអីនឹង!

ក៖ កាលនឹងក្នុងមួយខែបងបានប៉ុន្មានដែរ?

ខ៖ បានថោកដែរនឹងអូនបានតែ ៥០$ កាលនៅជំនាន់១៩៧៩ និងប្រាក់ខែបងបានតែ ៥០$ នឹង
ហើយធ្វើការអោយហាងជនជាតិផង
បងគ្មានចេះអីទេចេះតែលាងចានជូតឥដ្ឋជូតអីអោយគេនឹង!

ក៖ ហាងនឹងឈ្មោះអីដែរបង?

ខ៖ កាលពីពួកបងនៅក្រមុំៗបងធ្វើការតែនៅក្នុងហាងទេ
ដល់ពេលធ្វើការនៅក្នុងហាងនឹងឆ្អែតឆ្អន់នឹងទៅក៏បែកគំនិតទៅធ្វើការនៅរោងចក្រអស់ទៅ
ហើយបងប្អូនបងនឹងអាមួយធ្វើការនៅរោងចក្រនឹងលូ៥
ហើយម្នាក់ទៀតធ្វើការនៅរោងចក្រនៅជំពូវ័ន្ត
ហើយបងក៏មិនដឹងថាគេធ្វើខាងអីដែរនឹងទាល់តែជួបវាផ្ទាល់បានដឹង
បើបងវិញមិនដឹងទេព្រោះមិនដែលធ្វើផងចឹងបងមិនដែលដឹងថាគេធ្វើអីខ្លះចឹងហ្មាអូន
គេធ្វើអីខ្លះយើងអត់ដឹង!

ក៖ ចុះចំណែកបងវិញនោះបង?

ខ៖ បងខ្ញុំហ៎?

ក៖ អត់ទេបងផ្ទាល់នឹង?

ខ៖ ខ្ញុំហ៎?

ក៖ ចាស បងធ្វើការនៅឯណាដែរ?

ខ៖ អូ! ធ្វើការនៅហាងក្បែវិមានឯករាជ្យយើងនឹង តែឥលូវបងឈប់ធ្វើហើយអូន!

ក៖ ចាស កាលនឹងបងធ្វើការនៅនឹងរកចំណូលបានចឹងបងសន្សំបានប៉ុន្មានដែរបង?

ខ៖ ហ៊ឹម!! បងទៅធ្វើការនឹងនៅជាមួយបងចឹងហើយពេលបើកបានមួយខែចឹងសន្សំបានមាសមួយជីអីចឹងទៅណាអូន
ធ្វើចឹងទៅពីរខែពីរជីចឹងទៅអោយម៉ែគាត់ទុកទៅដេកបងមិនជាចាយអីដេកនឹងហូបនៅនឹងកន្លែងធ្វើការនឹង
ហើយទុកមួយម៉ឺនពីរម៉ឺនចាយទៅព្រោះយើងមិនត្រូវចាយវាយអីផងហូបចុកលើគេទាំងអស់ហើយនឹងមានត្រូវចាយលើអីទៀតទេ
តែគ្រាន់តែថាយើងទុកខ្លះទៅគ្រាន់ទិញថ្នាំសំកូវអីពេលឈឺម្តងៗនឹងណា!

ក៖ កាលនឹងបងសន្សំបានលុយគួរសមដែរនឹង!

ខ៖ កាលបងនៅក្មេងៗបងសន្សំលុយអោយម៉ែឪជំពាក់គេទេ
ដល់ឥលូវកូនៗបានប្តីមកម៉ែឪជំពាក់គេរាប់លាន
កាលពីក្មេងអត់ទេដឹងតែថារកលុយបានអោយទុកទិញមាសទិញអីទុកចាយវាយទៅអោយតែបានលុយផ្ញើរអោយម៉ែអស់ៗហើយមិនដែលទុកខ្លួនឯងទេ
ពីរនាក់បងប្អូនចឹងទុកលុយតិចតួចនឹងទៅគ្រាន់វាយក្រៅតិចតួចនឹង!

ក៖ ហើយបងជួយផ្ញើរលុយអោយគាត់រាល់ខែដែលទេ?

ខ៖ ចាស ផ្ញើរអោយគាត់រាល់តែខែនឹង! មិនដែលដាច់ទេអូន!

ក៖ ចាស ហើយពេលបងមានស្វាមីហើយបងមិនបានធ្វើការទៀតទេន៏?

ខ៖ អត់បានធ្វើការអីទេអូន នៅតែផ្ទះនឹង!

ក៖ ចាស នៅក្នុងជីវិតរបស់បងតាំងពីតូចរហូតមកដល់ពេលនេះបងពិបាកទៅលើអ្វីខ្លះបង?

ខ៖ ពិបាកនោះមានតែយើខ្វះខាតលុយចិញ្ចឹមកូនពេលកូនឈឺម្តងៗចឹង
យើងពិបាកព្រោះត្រូវជួលផ្ទះជួលសំបែងគេនឹងត្រូវចំណាយរាល់ខែនឹង នៅថ្លៃទឹកភ្លើង
ពិបាកម៉ាចប់នឹងអូនអើយមានអីស្រួលទេ(សំលេងក្មេងយំ)!

ក៖ ចាស ហើយចឹងបង.....

ខ៖ កាន់តិចមើលប៉ា (បងស្រីនិយាយជាមួយប្តីរបស់គាត់)
មើលវាចេះទាញពងទាហើយមើលវា!!!

កៈ ចាស ក្រៅពីរឿងពិបាកៗដែលបងបានឆ្លងកាត់មកនៅក្នុងជីវិត តើបងមានរឿងអីដែលជាអនុស្សាវរីយ៍ល្អៗដែលគ្រប់ពេលដែលបងនឹកឃើញហើយធ្វើអោយបងសប្បាយចិត្តណាបង?

ខៈ មានអីសប្បាយចិត្តអូនពេលដែលប្ដីរកបានទៅសប្បាយចិត្តទៅ ពេលកូនមិនឈឺទៅសប្បាយចិត្តទៅមានពិបាកអី!

កៈ ហើយចុះស្វាមីរបស់បងគាត់ធ្វើការអីធ្វើអោយសប្បាយចិត្តបង?

ខៈ ធ្វើអីអូន គ្រាន់តែកុំអោយផឹកស៊ីនឹងទៅ កុំកូរយើងទៅបានហើយ បើប្ដីកូរយើងដែរបានអីសប្បាយចិត្ត!

កៈ ចឹងបងសុំតែកុំអោយលោកពូនឹងគាត់..........

ខៈ កុំអោយគាត់ផឹកច្រើនទៅ ហើយនៅផ្ទះនៅសំបែងជួយមើលថៃកូនទៅបងសប្បាយចិត្តណាស់ទៅហើយ បើគាត់ផឹកម្ដងៗម៉ោង១១,១២ យប់អីនៅមិនទាន់ឈប់ផងនឹង ហើយពេលផឹករួចរាល់ហើយនៅមករករឿងយើងទៀតបងពិបាកចិត្តណាស់អូនម្ដងៗនឹងពិបាកណាស់ រាល់ថ្ងៃបងបាក់ទឹកចិត្តណាស់អូន!

កៈ ចាស ហើយចុះគាត់ផឹករាល់ថ្ងៃហ្អែសបង?

ខៈ នឹងហើយអូន!

កៈ អឹម! ចុះបងស្រីមានធ្លាប់ប្រាប់គាត់ដែរទេបង?

ខៈ ធ្លាប់ប្រាប់ធ្លាប់និយាយតែវានៅតែមិនកែ វាមានតែជេរយើងបញ្ចោរយើងថែមនឹង!

កៈ ចាស ហើយចឹងគាត់មានធ្លាប់វាយធ្វើបាបគាត់ទេ?

ខៈ (ប្ដីនៅជិតមិនហ៊ាននិយាយ)!

កៈ ចាស ចឹងពេលដែលបងមានស្វាមីមានកូនហើយដែរ ហើយចុះបងមានគំរោងធ្វើអ្វីដើម្បីផែនការជីវិតរបស់បងទៅថ្ងៃអនាគត់ដែរឬទេ?

ខៈ ហ៊ើយបងមិនដឹងទៅធ្វើអី បើបងជាប់មើលកូននឹងមានធ្វើអីកើត ចង់នោះចង់ហើយអូនតែយើងដៃទាល់ជើងទាល់មិនដឹងថាទៅធ្វើអីកើត!

កៈ ហើយចុះបងចង់បានអីដែរបង?

ខៈ សំរាប់បងចង់បានតែមុខរបររកស៊ី ទុកគ្រាន់ចិញ្ចឹមកូនមានលុយទុកសំរាប់កូនឈឺនឹងទៅ បងមិនដឹងថាទៅរកអីទេអូន!

កៈ ចាស ហើយបងមានបំណងប្រាថ្នាអីដែរបង?

ខៈ ដូចបងប្រាប់ចឹងអូនបងចង់បានតែមានមុខរបរត្រឹមត្រូវមួយចឹង មានផ្ទះជារបស់ខ្លួនឯងនឹងទៅ ហើយអាចមានជីវភាពធូរធារសំរាប់ចិញ្ចឹមកូននឹងទៅបានហើយអូន!

កៈ ចាស ហើយកាលពីបងនៅក្មេងវិញបងប្រាថ្នាចង់ក្លាយជាអីដែរពេលដែលបងធំឡើង?

ខៈ កាលនៅពីក្មេងមិនដែលនឹកឃើញថាមានបំណងប្រាថ្នាថាធំឡើងនឹងចង់ក្លាយជាអីទេ មិនដែលចេះដឹងអីទេដឹងតែថាធ្វើការបានលុយទៅអោយលុយម៉ែឪ (សំលេងកូនយំ) មិនដឹងថាការងារអីទេ អោយតែមានការងារធ្វើចេះតែធ្វើតែធ្វើទៅនៅពីក្មេងអោយតែបានលុយចេះតែធ្វើទៅ!

កៈ ចាស ហើយបងពេលដែលបងធ្លាប់ឆ្លងកាត់មកនៅក្នុងជីវិតទាំងសប្បាយក៏មានកើតទុក្ខក៏មាន ហើយចុះសព្វនេះបងគិតថាបងសប្បាយចិត្តនឹងជីវិតខ្លួនឯងទេ?

ខៈ សប្បាយចិត្តអីឈឺចង់ងាប់ចង់រស់នឹង (សើច)!

កៈ បងឈឺអីគេខ្លះដែរបង?

ខៈ ឈឺបេះដូង ហត់ៗនឹងចេះតែហត់ក្បាលនឹងចេះតែឈឺមិនឈប់ឈឺសព្វបែបយ៉ាងនឹង (សំលេងក្មេងយំ) រោគបងនឹងគឺហត់នឹងម៉ងហត់ចំឡែក រាល់ថ្ងៃមិនដែលសប្បាយចិត្តនឹងជីវិតរបស់ខ្លួនឯងម៉េច ចុះបើយើងឈឺរហូតនឹង!

កៈ ចាស ហើយចុះបងស្រីមានបានទៅពេទ្យដែរទេ?

ខៈ ពីមុនទៅអូន ដល់ឥលូវមិនដែលទៅទេអូន ព្រោះគេមើលមិនជាទេបើយើងឈឺតាំងពីអាយុ១៥ ឆ្នាំ គ្រាន់ទេដេកនៅពេទ្យរុស្សីស៊ីរ៉ុមទាំងឡូ (សើច) មានបានទៅណា បើយើងចាប់ផ្ដើមឈឺនឹងតាំងពីយើងនៅលីវនៅក្រមុំ នៅអាយុ១៤ ឆ្នាំ ១៥ ឆ្នាំ ឈឺរហូតមកដល់រាល់ថ្ងៃក៏នៅតែឈឺមើលមិនជា

ទៅមើលនៅពេទ្យចឹងទៅពេលណាគ្រាន់បើមួយភ្លែតទៅពេលណាត្រូវឈឺៗចឹងទៅ គេមើលមិនជាគេថាយើងរោគប្រចាំកាយ!

ក៖ អូ!! ចាស ពេទ្យគេនិយាយចឹងហ៎បង?

ខ៖ ចាស គេថារោគនឹងរោគប្រចាំកាយ!

ក៖ ចាស នៅស្ងៀមៗចឹងហាត់មែនបង?

ខ៖ ហាត់ ហើយរកគេអោយកោសខ្យល់អោយទៅបានធូរទៅ ហើយធ្វើទុកក្រពះតិចតួចចឹងទៅ ក្រពះនឹងក៏ចឹងដែរខ្ញុំមើលមិនជាដែលនឹង
ពេលណាថ្នាំខ្លាំងពេកលេបហើយធ្វើទុកយើងវិលអស់ហើយវិលអស់
វាធ្វើទុកបងខ្លាំងពេកបងក៏ឈប់លេបទៅ ផឹកបានទេថ្នាំអក្សរពេនឹង!

ក៖ ចាស ហើយចឹងបងមានជំងឺពីរមុខនឹងក្រពះនឹងឧស្សាហ៍ហាត់?

ខ៖ ចាសឈឺក្រពះនឹងឧស្សាហ៍ហាត់!

ក៖ ហើយអឺ!! ជំងឺនឹងវាធ្វើទុកខ្លាំងនៅពេលណាដែរបង?

ខ៖
វាមិនដែលទៅធ្វើទុកខ្លាំងសន្លប់អីទេគ្រាន់តែថានៅស្ងៀមៗចឹងវាធ្វើទុកហាត់ៗចឹងទៅយើងកោសខ្យល់ទៅវាចឹង
មកពីដំបូងនឹងបងដេកពេទ្យជ្រុលរាប់ខែមិនចេញទៅណាសឹងតែថាយកមន្ទីរពេទ្យធ្វើជាផ្ទះទៅហើយនឹងកាលបងនៅក្មេងចុះយើងភ័យហើយឪម្ដាយយើងគាត់ក៏ដែរយកបងទៅពេទ្យដេកនៅនឹងពេទ្យអស់ចិត្តអស់ចង់ហើយក៏នៅតែមិនបាត់ចឹងហើយដល់ពេលដែលបងរៀនធំចឹងទៅហើយណាមួយយើងក៏ស៊ាំនឹងជំងឺនឹងទៅហើយដែរក៏មិនបាច់ទៅពេទ្យអីទៀតឈឺល្មមនឹងយើងទៅរកគេអោយជួកកោសខ្យលទៅហើយដល់តែយើងយូរទៅមានអារម្មណ៍ថាវាធម្មតាសំរាប់យើងទៅហើយដូចថាយើងវាលែងភ័យស្លន់ស្លោដូចការដែរបងនៅក្មេងៗណាស់ យើងដឹងខ្លួន
ឯងហើយមើលតែមិនស្រួលឆាប់ហៅគេអោយកោសខ្យលអោយទៅកោសហើយធូរទៅវិញទៅ!

ក៖ ចាស ហើយម៉េចកាលនឹងទៅយូរម្លេះបង?

ខ៖ ចុះបើយើងមិនជាវានៅតែឈឺចឹងរហូតនឹង!

ក៖ ពេទ្យគេនៅតែថានៅតាមដានចឹងរហូតទៅ?

ខ៖
នឹងហើយគេចេះតែមើលទៅដល់ពេលយើងហាត់យើងរត់ពេលយើងរត់ទៅដល់តែយូរៗទៅដូចថាយើងសុំាក៏លែងទៅ
ហើយបណ្តោយវាទៅតាមដំណើរនឹងទៅបើដឹងហើយថាវានៅតែចឹងកាលមុននឹងយើងនៅក្មេងចេះតែទៅដេកកន្លះខែមួយខែមកវិញមកៗទៅដល់តែឥលូវនេះមានកូនមួយពីរអាយុ៣០
៤០ក៏លែងទៅៗពេលហាត់កោសខ្យល់ៗទៅ!

ក៖ ចាស បងគិតថាទោះតែទៅពេទ្យក៏វានៅតែដដែលហ៎បង? យើងអាចទ្រាំនឹងជំងឺនឹងបានហើយ វាស៊ាំទៅហើយន៏បង?

ខ៖ ចាស!! បើកាលនៅក្មេងបានភ័យ អូ!!
កាលនឹងពេលធ្វើទុករើឡើងម្តងៗចឹងដឹងតែទៅដល់ពេទ្យហើយមិនដូចឥលូវធ្វើទុកនឹងរត់រកគេអោយកោសខ្យល់អោយទេណា!

ក៖ ដូចថាយើងស៊ាំទៅនឹងជំងឺនឹងទៅហើយន៏បង!

ខ៖ ចាស បើកាលនៅពីក្មេងៗទៅដេកពេទ្យឡើងពេទ្យថាមិនដឹងជាឈឺស្អីទេបើសាច់ម្លឹងៗដេករហូតដល់ពេទ្យៗម្នាក់ៗមកលេងចឹងទៅម្នាក់ស្រលាញបងណាស់គ្រូពេទ្យៗនឹងណាស់!

ក៖ ឡើងពេទ្យស្គាល់មុខអស់ហើយ (សើច)!

ខ៖ ចាស ពេទ្យស្គាល់មុខអស់ហើយស្រលាញ់ណាស់! ហើយចំពេទ្យស្តារកំលោះៗនោះ
ហើយកាលនឹងពេទ្យស្តារនៅវត្តយើងនេះគេស្រលាញ់យើងចឹងណាស់
ដល់ហើយវាមិនអោយម៉ែឪវាមកចូលដណ្តឹងចឹងណាស ដូចថាគេស្រលាញ់យើង
ហើយវាមកសុំយើងសែនហើយធ្វើដល់ទៅពេទ្យមកសុំយើងសែនាវាស្រលាញ់យើងតែដូចថាម៉ែឪវាមិនដឹងវាមិនអោយម៉ែឪវាចូលដណ្តឹងយើងវាគិតតែខ្លួនឯង
តែយើងនិស្ស័យរស់នៅជាមួយគ្នាចឹងបានត្រឹមតែស្រលាញ់នឹងទៅ
ទៅដេកពេទ្យទាល់តែពេទ្យស្រលាញ់!

ក៖ ចាស កាលនឹងម៉េចក៏បង អឺ..... ដូចថាអត់មាននិស្ស័យជាមួយគ្នាចឹងណាបង?

ខ៖ វាស្រលាញ់ហើយមកសុំម៉ែឪយើងរៀប ហើយសែនតិចតួចចឹងគាត់មិនព្រមក៏ដាច់គ្នាទៅ
ម៉ែឪខ្ញុំគាត់កូនខ្ញុំមិនដែលមានសែនអីចឹងទេហើយក៏គាត់អត់យល់ព្រមទៅ
ទៅយកអីបើគេសុទ្ធតែពេទ្យនឹង
ហើយធ្វើដល់ពេទ្យតែមកសុំយើងរៀបហើយម៉ែឪយើងគាត់មិនចូលចិត្តចឹងណា
គេក៏ទៅតាមដំណើរគេនឹងទៅ!

ក៖ អឹម........គេមិនមកសុំបងរៀបការអីទេ?

ខ៖ អត់!!!
វាស្រលាញ់ក៏ចិត្តវាហើយមកមិយាយជាមួយម៉ែឪយើងក៏ខ្លួនវានឹងទៅមិនមានម៉ែឪវាណានឹងម
កចូលស្ទួរយើងត្រឹមត្រូវផង
ចឹងហើយម៉ែឪគាត់មិនព្រមទេហើយក៏គេទៅដោយគេទៅហើយយើងទៅដោយយើងទៅ
យើងគ្មាននិស្ស័យជាមួយគ្នានិយាយអោយចំទៅយើងមិនមែនជាគូនឹងយើងណាសអូន!

ក៖ ចាស ហើយចុះរាល់ថ្ងៃបងនៅចាំមុខគាត់ទេ?

ខ៖ មិនចាំទេ!!
ទោះជាឥលូវឃើញគ្នាក៏មិនស្គាល់ដែរបើម្នាក់ៗចាស់រៀងៗខ្លួនអស់ហើយនឹងមានបាននៅចាំ
គ្នាទេ
ម្នាក់ៗប្រែប្រួលអស់ហើយយើងក៏មានប្តីហើយគេក៏មានប្រពន្ធទៅហើយដែរតាមមើលទៅ
នោះ!!

ក៖ អត់ចាំទេ ភ្លេចបាត់ហើយ យូរឆ្នាំហើយ!

ខ៖ នឹងហើយយូរឆ្នាំហើយ គិតទៅតាំងពីអាយុ២០ ឆ្នាំហើយមកដល់ឥលូវម្ភៃឆ្នាំហើយ!

ក៖ ចាស ហើយបងពេលដែលបងនៅក្មេងៗបងចូលចិត្តលេងល្បែងអីជាងគេ!

ខ៖ អត់ដូចជាមិនចូលចិត្តលេងល្បែងអីផង!

ក៖ អឹម........ល្បែងប្រជាប្រិយបង?

ខ៖ អូ! ល្បែងប្រជាប្រិយចូលឆ្នាំអីនឹងហ្អែស?

ក៖ ចាស!!

ខ៖ (សើច) ល្បែងប្រជាប្រិយម៉ាចប់ចូលឆ្នាំនឹងសប្បាយសឹងអី លេងខ្លាស៊ីគោ លាក់កន្សែងអីនឹង ចោលឈូងអីនឹងសប្បាយណាស់មានគ្រប់ប្រភេទនឹង មិនដូចឥលូវមិនចេះលេងអីទេ កាលនៅក្មេងអោយតែជិតដល់ចូលឆ្នាំជិតមួខែនឹងលេងអង្គុញ លេងអ៊ូ សប្បាយណាស់ពេលដែលចេញពីធ្វើការមកម៉ោងបួនម៉ោងប្រាំនឹង ហើយយប់ឡើងនាំគ្នាលេងតាមផ្លូវកំលោះក្រមុំៗឡើងគរមិនដូចឥលូវទេ កាលណោះទាំងបងទាំងគេនឹងមកជុំគ្នាអោយយប់ឡើងពេលណាចេញពីធ្វើការដឹងតែនាំគ្នាលេងទាំងអស់គ្នានឹង! អូ!!! សប្បាយណាស់អូនលេងចឹងមិនដែលចេះប្រកាន់គ្នាទេទាំងប្រុសទាំងស្រីនឹងមកលេងជុំៗគ្នានឹង លេងហើយចឹងស្អែកឡើងធ្វើការ!

ក៖ កាលនឹងលេងជាមួយមិត្តភក្តិហ្អែសបង?

ខ៖ លេងជាមួយមិត្តភក្តិ បងប្អូន អ្នកផ្ទះជួលនឹង ស្រីៗក្រមុំៗដូចគ្នានឹងមកពីធ្វើការវិញបាយហើយនាំគ្នាមកលេងហើយខោអាវត្រាំដាក់ចោលនឹងចានដែកក្នុងកាធុននឹងហើយទៅលេងហើយសប្បាយណាស់!

ក៖ ចាស ហើយចុះបទចំរៀងបងចូលចិត្តស្តាប់បទចំរៀងអីដែរ?

ខ៖ បងសំរាប់បទចំរៀងដូចជាមិនដឹងថាចូលចិត្តបទណាទេដូចតែមនុស្សយន្តមិនដឹងថាចូលចិត្តអី បងមិនសូវជាចាប់អារម្មណ៏ចឹងៗដូចថាបេះដូងយើងខ្សោយយើងមិនសូវជាចូលចឹងៗណាស់ ពេលណាគេចាក់ចំរៀងលឺៗខ្លាំងខឹងនឹងគេទៀតណាស់យើងវាមិនសូវជាស្រួលខ្លួននោះ!

ក៖ ចាស ចឹងបងមិនសូវចូលចិត្តបទចំរៀងន៏បង?

ខ៖ ចាសអូន!

ក៖ ចាស ហើយបងក៏មានវ័យនឹងជ្រេបន្តិចហើយដែរហើយក៏ធ្លាប់ឆ្លងកាត់នូវបទពិសោធន៏នៃជីវិតនឹងក៏ច្រើនហើយណាស់ដែរ ចឹងតើបទពិសោធន៏ក្នុងជីវិតបងមួយណាដែលធ្វើអោយចងចាំនៅក្នុងចិត្តរហូតមិនអាចបំភេចបានចឹងណា?

ខ៖ រឿងដែលបំភ្លេចមិនបានមានតែរឿងដែលយើងឈឺនឹងដូចថាយើងឈឺច្រើន!

ក៖ ពេលឈឺម្ដងៗវាចេះតែពិបាកក្នុងខ្លួនចឹងទៅ?

ខ៖ នឹងហើយដល់តែយើងឈឺច្រើនចឹងទៅវាមិនធ្វើអោយយើងមិនសប្បាយចិត្តងាកឈឺៗម៉ងនឹងណា បើចឹងៗមិនដឹងថាសប្បាយចិតម៉េចទេបើឈឺរហូតចឹងឈឺនឹងឈឺប្រចាំត្រូវឈឺក៏ឈឺមួយភ្លេតចឹងទៅដូចយើងនឹងមាយាចឹងណា ហើយដល់ពេលបានប្ដីក៏គេមិនយល់ចិត្តទៀត!

ក៖ ចាសបង ហើយចឹងជាចុងក្រោយបងមានពាក្យពេជ្យអីដល់អ្នកដែលបានស្ដាប់សំលេងរបស់បងទាក់ទងទៅនឹងជីវិត ការតស៊ូ ឬក៏អ្វីដែលបងធ្លាប់ជួបប្រទះដើម្បីអោយអ្នកជំនាន់ក្រោយគេបានស្ដាប់ហើយក៏យកបទពិសោធន៍ល្អៗរបស់បងនឹងទៅអនុវត្តន៍ចឹងណាបង?

ខ៖ មានអីទេ មានតែកុំអោយដូចខ្ញុំ កុំអោយគេដូចយើងចឹងណាស់!!

ក៖ ដូចម៉េចខ្លះទៅបង?

ខ៖ ដូចថាយើងមិនចេះអីចឹងហើយយើងនឹងល្ងិនល្ងង់ច្រើនមិនសូវចេះអក្សរចឹងពិបាកណាស់អូនហើយដល់ពេលបានប្ដីក៏មិនស្រណុកស្រួលកុំអោយគេអភ័ព្វដូចយើងអោយគេល្អជាងយើងទៅ ហើយអោយក្មេងជំនាន់ក្រោយនឹងខិតខំរៀនសូត្រទៅទាន់ខ្លួននៅក្មេងកុំអោយខ្ជិលដូចបងមើលបងជាគំរូមួយហើយកាលណាមិនចេះអក្សរវាពិបាកដូចបងចឹងណាស់ ទៅធ្វើការប្រាក់ខែមិនបានថ្លៃដូចគេចេះអក្សរទេ ហើយដល់បានប្ដីក៏គេចេះដឹងគ្រាន់បើជាងយើងពេលខ្លះទៅគេមើលងាយយើងណាសគេធ្វើអីចឹងយើងម៉េចដឹងបើគេចេះយើងមិនចេះផង យើងតាមគេមិនទាន់ចឹងបានថាបងសុំផ្ដាំទៅដល់ប្អូនៗប្រឹងប្រែងរៀនសូត្រឡើងកុំខ្ជះខ្ជាយពេលវេលាហើយក៏កុំខ្មាសអៀនក្នុងការរៀនតែខ្មាសដឹងតែល្ងង់ខ្លៅដូចបងចឹង ហើយត្រូវចេះថែទាំសុខភាពអោយបានល្អកុំឈឺដូចបងៗពិបាកណាសពេលឈឺខាតពេលខាតលុយគ្មានចំណេញទេ ហើយមួយទៀតកាន់តែសំខាន់នោះត្រូវតែចៀសវាងអោយឆ្ងាយពីគ្រឿងញៀនកុំឡូកឡំជាមួយគ្រឿងញៀននឹងវាមិនល្អចំពោះសុខភាពទេមានតែនាំយើងទៅរកផ្លូវអប្បាយមុខធ្វើអោយ

ម៉ែឪ ឪពុកម្តាយពួកគាត់អាប់អោនកេរ្តិ៍ឈ្មោះ រងនូវការអាម៉ាសពីញ្ញាតិជិតខាងទេត្រូវធ្វើខ្លួបអោយល្អ ដើម្បីអនាគតយើងអូន!

ក៖ ចាស ហើយបងមានអ្វីបន្ថែមទៀតទេ?

ខ៖ អត់មានទេអូន!

ក៖ ចាសចឹងខ្ញុំសុំអរគុណាច្រើនដែលបងស្រីចំណាយពេលអោយខ្ញុំបានសំភាសន៍ សុំជូនពរអោយបងស្រីឆាប់ជាពីជំងឺមានសុខភាពល្អប្របកមុខរបររកស៊ីលក់ដូរកាក់កប ហើយនិងមានសុភមង្គលនៅក្នុងក្រុមគ្រួសារ ចាសសុំអរគុណាច្រើនបង!

ខ៖ចាសអូន!!